## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Feb-2011, 15:14
CMS/CFO: Sann Rada

### ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សេចក្តីសង្ខេតរបស់ សហព្រះរាជអាជ្ញា លើញត្តិរបស់ អៀង សារី ដែលសុំដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ចម្លងជូន:**

| សហមេធាវីនាំមុខ តំណាងដើមបណ្តឹង រដ្ឋប្បវេណី: | ជនត្រូវចោទ: | ក្រុមមេធាវីជនជាប់ចោទ: |
|---|---|---|
| លោក ពេជ អង្គ | នួន ជា | លោក សុន អរុណ |
| Elisabeth SIMONNEAU FORT | អៀង សារី | លោក Michiel PESTMAN |
| | អៀង ធីរិទ្ធ | លោក Victor Koppe |
| | ខៀវ សំផន | លោក អាង ឧត្តម |
| | | លោក Michael G.KARNAVAS |
| | | លោក ផាត់ ពៅស៊ាង |
| | | កញ្ញា Diana ELLIS QC |
| | | លោក សរ ស្វាន |
| | | លោក Jacques VERGÈS |
| | | លោក Philippe GRÉCIANO |

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ*

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ ជនជាប់ចោទឈ្មោះ អៀង សារី ("ជនជាប់ចោទ") បានដាក់ញត្តិស្នើសុំឱ្យដំណើរការសវនាការរយៈពេលកន្លះថ្ងៃ ("ញត្តិស្នើសុំ")[1]។ សហព្រះរាជអាជ្ញា សូមជំទាស់នឹងសំណើសុំឱ្យដំណើរការសវនាការរយៈពេលកន្លះថ្ងៃនេះ ពីព្រោះការលើកឡើងអះអាងអំពីសុខភាពទ្រុឌទ្រោម និងស្ថានភាពខាងផ្លូវកាយ របស់ជនជាប់ចោទមិនត្រូវបានគាំទ្រដោយរបាយការណ៍វាយតម្លៃណាមួយរបស់ផ្នែកពេទ្យនោះឡើយ។

២. លើសពីនេះ សហព្រះរាជអាជ្ញា នឹងដាក់សេចក្តីសន្និដ្ឋានស្តីពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងដំណើរការនីតិវិធីពីកន្លែងណាមួយពីចម្ងាយដោយប្រើប្រាស់បច្ចេកវិទ្យាសោតទស្សន៍ និងទូរទស្សន៍ផ្សាយបន្តផ្ទាល់ ក្នុងករណីសវនាការត្រូវបានអាក់ខានជាចាំបាច់ដោយសារមូលហេតុអវត្តមានរបស់ជនជាប់ចោទពីក្នុងអង្គជំនុំជម្រះសាលាដំបូង។

## ២. សំណើសុំឲ្យធ្វើសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ គួរត្រូវបានបដិសេធចោល ពីព្រោះមិនមានការគាំទ្រដោយភស្តុតាងណាមួយរបស់ពេទ្យឡើយ

៣. ជនជាប់ចោទអះអាងថា ស្ថានភាពសុខភាព និងខាងផ្លូវកាយរបស់គាត់រារាំងមិនអោយគាត់ អង្គុយក្នុងបន្ទប់សវនាការក្នុងរយៈពេលយូរបាន។ គាត់លើកឡើងថាមានបញ្ហាផ្នែកខ្នង បញ្ហាទឹកនោម ក៏ដូចជា មានរោគាផ្សេងៗក្នុងការរក្សាឋាមពលរបស់គាត់ និងការផ្ចិតផ្ចង់ផ្តោតអារម្មណ៍ក្នុងរយៈពេលយូរ។ ក៏ប៉ុន្តែ មិនមានរបាយការណ៍វាយតម្លៃរបស់ពេទ្យណាមួយដែលចង្អុលបង្ហាញភស្តុតាងចំពោះសំណើនេះដែលត្រូវបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងទេ។ អំនះអំណាងតែមួយគត់ដែលគាំទ្រចំពោះសេចក្តីថ្លែងនេះ គឺថាក្រុមមេធាវីការពារក្តីមិនអាចជួបជនជាប់ចោទលើសពីមួយម៉ោងបានទេក្នុងមួយលើកៗ ហើយក៏មិនឱ្យហួសពីរម៉ោងបានដែរក្នុងមួយថ្ងៃ ហើយថាគាត់ត្រូវចូល

[1] ញត្តិរបស់ អៀង សារី សុំឱ្យដំណើរការសវនាការរយៈពេលកន្លះថ្ងៃ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក /អជសដ, ការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ មករា ២០១១ [" ដែលជាបន្តទៀតហៅកាត់ថា ញត្តិរបស់ អៀង សារី"]។

បន្ទប់ទឹកយ៉ាងតិចក៏ពីរដងរៀងរាល់អម្តងពេលមួយម៉ោងក្នុងជំនួបនេះ[2]។ អំណះអំណាងនេះគឺមិនទាន់គ្រប់គ្រាន់ដើម្បីគាំទ្រចំពោះញត្តិស្នើសុំនេះទេ ប្រសិនបើយល់ព្រមអនុញ្ញាតតាមនេះ គឺមុខជានឹងធ្វើឱ្យរយៈពេលដែលតម្រូវសម្រាប់ធ្វើសវនាការជំនុំជម្រះក្តីត្រូវកើនឡើងទ្វេរដង។ .

៤. តុលាការអន្តរជាតិនានា បានយល់ព្រមអនុញ្ញាតលើញត្តិស្នើសុំឱ្យបន្ថយរយៈពេល នៃដំណើរការសវនាការជំនុំជម្រះក្តីប្រចាំថ្ងៃ ឬលើកពេលសវនាការ ប៉ុន្តែការអនុវត្តដូចនេះគឺដោយផ្អែកលើមូលដ្ឋាននៃរបាយការណ៍វេជ្ជសាស្ត្រជាលាយលក្ខណ៍អក្សរនិង/ឬការផ្តល់សក្ខីកម្មរបស់គ្រូពេទ្យណាម្នាក់[3]។ សហព្រះរាជអាជ្ញាមិនឃើញថាមានមូលហេតុអ្វី ចេញពីការអនុវត្តបែបនេះទាល់តែសោះ ក្នុងករណីរឿងសំណើសុំនេះ។

៥. ហេតុដូចនេះ ដោយសារនៅក្នុងពេលនេះមិនមានមូលដ្ឋានដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការសុំបន្ថយរយៈពេលដំណើរការសវនាការជម្រះក្តីដោយហេតុផលស្ថានភាពខាងផ្លូវកាយ ឬសុខភាពទ្រុឌទ្រោមដោយមានជម្ងឺនោះ ដំណើរការសវនាការជំនុំជម្រះក្តីគួរតែត្រូវធ្វើជាប្រចាំថ្ងៃដូចធម្មតារហូតទាល់តែមានភស្តុតាងគ្រប់គ្រាន់ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង អាចធ្វើការវាយតម្លៃបានដោយត្រឹមត្រូវលើសំណើសុំបន្ថយម៉ោងក្នុងការធ្វើសវនាការរបស់ខ្លួន។

## ៣. ក្នុងករណីស្ថានភាពរបស់ជនជាប់ចោទធ្វើឲ្យមានការអាក់ខានដំណើរការសវនាការក្នុងសភាពធ្ងន់ធ្ងរ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអនុញ្ញាតឲ្យជនជាប់ចោទចូលរួមពីចម្ងាយនៅទីកន្លែងណាមួយបាន

[2] ញត្តិរបស់ អៀង សារី, លេខយោងចំណាំជើងទំព័រលេខ៨។

[3] *សូមអាន* ឧទាហរណ៍ដូចជា ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង Milosević,* មូលហេតុនៃសេចក្តីសម្រេចទាក់ទងនឹងការចាត់តាំងមេធាវី, សំណុំរឿង IT-02-54-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ថ្ងៃទី២២ កញ្ញា ២០០៤ កថាខណ្ឌ១៣, ៥៣-៥៤ (តុលាការយោងទៅលើរបាយការណ៍មួយពីបណ្ឌិត van Dijkmanឱ្យលើកពេលសវនាការនិងណែនាំដល់គ្រូពេទ្យឯកទេសខាងបេះដូងធ្វើការពិនិត្យមួយទៅ លើជនជាប់ចោទ) និងករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង Stanišić & Simatović*, ដីកាកំណត់កាលវិភាគសម្រាប់ការបើកសវនាការ , អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, សំណុំរឿងលេខ IT-03-69-PT, ICTY,ចុះថ្ងៃទី ៣ មេសា ២០០៨ និងថ្ងៃទី២២ មេសា ២០០៨ (អង្គជំនុំជម្រះបានស្តាប់ចម្លើយរបស់អ្នកជំនាញផ្នែកសរសៃប្រសាទនិងចិត្តសាស្ត្រ ដែលត្រូវបានតែងតាំងដោយក្រឡាបញ្ជីនៅមុនពេលធ្វើការកំណត់ណាមួយទៅលើសុខភាពរឹងមាំរបស់ជនជាប់ចោទដើម្បីចូលរួមដោយផ្ទាល់នៅក្នុងពេលសវនាការ)។

៦. ជនជាប់ចោទស្នើថា ការចូលរួមដោយប្រើបច្ចេកទេសសោតទស្សន៍ និងទូរទស្សន៍ផ្សាយបន្តនោះ គឺមិនអាចជំនួសឱ្យសិទ្ធិត្រូវមានវត្តមានរបស់គាត់នៅក្នុងពេលសវនាការបានទេ លុះត្រាតែមានការយល់ព្រមពីគាត់លើនីតិវិធីបែបបនេះ[4]។ សហព្រះរាជអាជ្ញា សូមបដិសេធចំពោះសំណើនេះ។

៧. ក្នុងនាមជាបញ្ហាទូទៅ បទដ្ឋានអន្តរជាតិស្តីពីការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌គឺរក្សាការពារសិទ្ធិរបស់ជនជាប់ចោទដើម្បីឱ្យបានទទួលនូវការជំនុំជម្រះក្តីដោយមានវត្តមានរបស់ខ្លួនគេ។ សិទ្ធិនេះត្រូវបានធានាដោយមាត្រា៣៥.ឃថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ[5] ("ច្បាប់ អវតក") និងដោយមាត្រា១៤.៣.ឃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ[6]("ICCPR") ។

៨. នៅតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("តុលាការ ICTY") និង តុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ("តុលាការ ICTR") បានបកស្រាយអំពី សិទ្ធិមានវត្តមាននៅក្នុងពេលសវនាការថា គឺមានន័យថា វត្តមានជារូបវន្តរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការ[7]។ ក៏ប៉ុន្តែ តុលាការទាំងពីរនោះ ភាគច្រើន ផ្អែកទៅលើប្រព័ន្ធច្បាប់ អង់គ្លោ-សាក់សុង។ អវតក យកតាមប្រពៃណីយ៍នៃប្រព័ន្ធច្បាប់បារាំង (civil law tradition) ដែលវត្តមានជារូបវន្តរបស់ជនជាប់ចោទផ្ទាល់នៅក្នុងពេលសវនាការជំនុំជម្រះក្តីគឺ មិនសំខាន់ចាំបាច់ដាច់ខាតសម្រាប់សិទ្ធិរបស់ជនជាប់ចោទ

---

[4] ញត្តិរបស់ អៀង សារី, កថាខណ្ឌទី ១១-១៣។

[5] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរួមបញ្ចូលទាំងវិសោធនកម្មមួយចំនួនដេលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៧ តុលា ២០០៤ (នស/រកម/១០០៤/០០៦) [ដែលជាបន្តទៀតក្នុងនេះហៅកាត់ថា "ច្បាប់ អវតក"]។

[6] កតិកាសញ្ញាអន្តរជាតិស្តីពិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ធ្នូ ១៩៦៦, 999 U.N.T.S 171,ដែលបានចូលជាធរមានកាលពីថ្ងៃទី ២៣ មីនា ១៩៧៦, មាត្រា១៤.៣.ឃ។

[7] ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង Zigiranyirazo,* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ករណីបន្ទាន់បង្ហំ, សំណុំរឿងលេខ ICTR-2001-73-AR73, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR, ចុះថ្ងៃទី៣០ តុលា ២០០៦ កថាខណ្ឌទី១២ [ដែលជាបន្តទៀតក្នុងនេះហៅកាត់ថា "អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ករណី *Zigiranyirazo*"]។ ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង Stanišić & Simatović*, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មេធាវីប្រឆាំងនិងសេចក្តីសម្រេចស្តីពីការធ្វើសវនាការនៅក្នុងពេលអនាគត, សំណុំរឿងលេខ IT-03-69-AR73.2, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី១៦ ឧសភា ២០០៨, កថាខណ្ឌទី៦ [ដែលជាបន្តទៀតក្នុងនេះហៅកាត់ថា "អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ករណី *Stanišić & Simatović*"] ។

ក្នុងការទទួលបាននូវភាពត្រឹមត្រូវយុត្តិធម៌នោះទេ។ ឧទាហរណ៍ដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងចែងថា សវនាការជំនុំជម្រះក្តីអាចបន្តធ្វើបាន ទោះបីបើសិនជាជនជាប់ចោទអវត្តមានដោយសារមូលហេតុសុខភាពក៏ដោយ[8]។ ហើយតុលាការ ពិសេសសម្រាប់ប្រទេសលីបង់ ("STL") ក៏មិនបានកំណត់ដាច់ខាតត្រូវតែមាន "វត្តមាន"ជារូបវន្តនោះដែរ អោយតែមាន "វត្តមានមេធាវី" របស់ជនជាប់ចោទគឺអាចគ្រប់គ្រាន់ថាជា "វត្តមាន" នៅក្រោមលក្ខខណ្ឌជាក់លាក់មួយចំនួន[9]។ វិធាន១០៤ និង១០៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL ចែងថា ជនជាប់ចោទណាម្នាក់ត្រូវបានចាត់ទុកថា មាន "វត្តមាន" ទោះបីជាជននេះចូលរួមដោយផ្ទាល់ តាមបច្ចេកទេសវីដេអូផ្សាយផ្ទាល់ (via video link) ឬ តាមរយៈមេធាវីការពារក្តី[10]។

៩. ក្នុងគ្រប់ករណីទាំងអស់ ទោះបីជាតាមការបកស្រាយតឹងរ៉ឹងជាងនេះ អំពី "វត្តមាននៅក្នុងពេលសវនាការ" ដែលអនុម័តយកដោយតុលាការ ICTY និង ICTR គឺតុលាការទាំងពីរនេះទទួលស្គាល់ថាសិទ្ធិក្នុងការមានវត្តមាននៅក្នុងពេលសវនាការគឺមិនមែនគ្មានការកំរិតកំណត់នោះទេ។ ឧទាហរណ៍ដូចជា វិធានរបស់តុលាការ ICTY និង ICTR, តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") គឺតុលាការនីមួយៗអនុញ្ញាតឱ្យធ្វើសវនាការដោយអវត្តមានរបស់ជនជាប់ចោទបាននៅក្នុងករណីបើសិនជនជាប់ចោទ បន្តរំខានដល់ដំណើរការសវនាការជំនុំជម្រះក្តី[11]។ ករណីនេះត្រូវបានបកស្រាយដោយតុលាការ ICTY និង ICTR ថា គឺ

---

[8] ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង មាត្រា៤១៦ ចែងថា: "Si le prévenu ne peut, en raison de son état de santé, comparaître devant le tribunal et s'il existe des raisons graves de ne point différer le jugement de l'affaire, le tribunal ordonne, par décision spéciale et motivée, que le prévenu, éventuellement assisté de son avocat, sera entendu à son domicile ou à la maison d'arrêt dans laquelle il se trouve détenu, par un magistrat commis à cet effet, accompagné d'un greffier. Procès-verbal est dressé de cet interrogatoire. Le débat est repris après citation nouvelle du prévenu, et les dispositions de l'article 411 , alinéas 1 et 2, sont applicables. Dans tous les cas, le prévenu est jugé contradictoirement." <u>សាលាវិនិច្ឆ័យប្រទេសបារាំងបានរកឃើញថា គឺវាមិនផ្ទុយនឹងសិទ្ធិរបស់ជនជាប់ចោទ ឬក៏ទៅនឹងមាត្រា៦ នៃអនុសញ្ញាសិទ្ធិមនុស្សរបស់ទ្វីបអឺរ៉ុបនោះដែរ ក្នុងការជំនុំជម្រះក្តីជនជាប់ចោទដែលអវត្តមានដោយសារមូលហេតុខាងសុខភាព ទោះបីជាគ្មានការយល់ព្រមរបស់ជនជាប់ចោទក្តី។ (សភាព្រហ្មទណ្ឌនៃសាលាវិនិច្ឆ័យ, ប្រទេសបារាំង, ចុះថ្ងៃទី២២ មករា២០០៣, ព្រឹត្តប័ត្រលេខ១៧)។</u>

[9] វិធានស្តីពីនីតិវិធីនិងភស្តុតាង: អនុស្សារណៈស្តីពីការពន្យល់ដោយប្រធានតុលាការ នៃតុលាការពិសេសសម្រាប់ប្រទេសលីបង់, ចុះថ្ងៃទី១០ វិច្ឆិកា ២០០៩, កថាខណ្ឌទី ៤១។

[10] តុលាការពិសេសសម្រាប់ប្រទេសលីបង់, វិធានស្តីពីនីតិវិធីនិងភស្តុតាង, ចុះថ្ងៃទី១០ មិថុនា ២០០៩, ដែលត្រូវបានពិនិត្យឡើងវិញកាលពីថ្ងៃទី ២៩ វិច្ឆិកា ២០១១, កថាខណ្ឌទី ១០៤-១០៥។

[11] វិធានផ្ទៃក្នុងនៃ អវតក ដែលត្រូវបានធ្វើវិសោធនកម្មកាលពីថ្ងៃទី១៧ កញ្ញា ២០១០, វិធាន៣៧.២ [ដែលបន្តមកទៀតហៅថា "វិធានអវតក"] ។ តុលាការប្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, វិធានស្តីពិនីតិវិធី និងភស្តុតាង, ដែលត្រូវបានអនុម័តកាលពីថ្ងៃទី២៩ មិថុនា ១៩៩៥, ត្រូវបានធ្វើវិសោធនកម្ម កាលពីថ្ងៃទី១ តុលា ២០០៩, វិធាន៨០.ខ។ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន, វិធានស្តីពីនីតិវិធី និងភស្តុតាង, ដែលត្រូវបានអនុម័ត កាលពីថ្ងៃទី១៦ មករា ២០០២, ត្រូវបានធ្វើវិសោធនកម្ម កាលពីថ្ងៃទី២៨ ឧសភា ២០១០, វិធាន៨០.ខ។ តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, វិធានស្តីពិនីតិវិធីនិងភស្តុតាង, ដែលត្រូវបានអនុម័ត កាលពីថ្ងៃទី១១ កុម្ភៈ ១៩៩៤,

ជាការអនុញ្ញាតឱ្យធ្វើសវនាការដោយមិនមានវត្តមានរបស់ជនជាប់ចោទ ទោះបីជាការរំខាននោះមិនមែនជាលទ្ធផលដែលកើតចេញមកពីការប្រព្រឹត្ត ដោយចេតនារបស់ជនជាប់ចោទក៏ដោយ[12]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY និង ICTR គឺតុលាការនីមួយៗបានបញ្ជាក់អះអាងអំពីសញ្ញាណថា ដំណើរការនីតិវិធីអាចត្រូវបានធ្វើឡើងដោយមិនមានវត្តមានរបស់ជនជាប់ចោទ ដើម្បីគោលបំណងជៀសវាងកុំឱ្យមាន "ការអាក់ខានដ៏ធំដុំដល់សវនាការ" ទោះបីជាការអាក់ខានទាំងនោះធ្វើឡើងដោយ " មិនមានចេតនា" ពីសំណាក់ជនជាប់ចោទក៏ដោយ ឱ្យតែការដាក់កំរិតទៅលើសិទ្ធិរបស់ជនជាប់ចោទដែលត្រូវទទួលការជំនុំជម្រះក្តីដោយមានវត្តមានរបស់ខ្លួនគេផ្ទាល់គឺជាចម្លើយតបមួយដែលមានភាពសមាមាត្រ[13]។ ដើម្បីវិនិច្ឆ័យថាតើចម្លើយតបមានភាពសមាមាត្រដែរឬទេនោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានពិនិត្យមើលទៅលើថាតើការកំរិតទៅលើសិទ្ធិរបស់ជនជាប់ចោទបាន "បំរើគ្រប់គ្រាន់ដល់គោលដៅសំខាន់ៗដែរឬទេ?" ហើយ"តើបានធ្វើឱ្យខូចខាតសិទ្ធិដោយមិនត្រូវឱ្យហួសពីការចាំបាច់ដើម្បីសម្រេចឱ្យបាននូវគោលដៅដែរឬទេ?"[14]។

១០. ការគួរឱ្យកត់សំគាល់ គឺអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ICTYបានបញ្ជាក់អះអាង អំពីគោលការណ៍នេះនៅក្នុងបរិបទ ដែលមានការប្រឆាំងតវ៉ាដោយជនជាប់ចោទអំពីសេចក្តីសម្រេចនៅក្នុងករណីរឿងរបស់*Stanišić& Simatović* ដែលក្នុងនេះ អង្គជំនុំជម្រះសាលាដំបូងកំណត់ថា សុខភាពដែលទ្រុឌទ្រោមដោយមានជម្ងឺរបស់ជនជាប់ចោទឈ្មោះ *Stanišić* ត្រូវបានអនុញ្ញាតឱ្យធ្វើបដិប្បញ្ញត្តិសិទ្ធិរបស់ខ្លួន អំពីវត្តមាននៅក្នុងតុលាការ ហើយបានបង្គាប់ឱ្យក្រឡាបញ្ជីបង្កើតការប្រជុំពីចម្ងាយដោយផ្សាយផ្ទាល់តាមខ្សែវីដេអូ ដើម្បីឱ្យជនជាប់ចោទមានលទ្ធភាពចូលរួមនៅក្នុងដំណើរការសវនាការបានពីអង្គភាពមន្ទីរឃុំឃាំង នៅក្នុងការដែលរូបគាត់មានសុខភាពទ្រុឌទ្រោមខ្លាំងពេកមិនអាចចូលរួមដោយខ្លួនឯងផ្ទាល់នៅក្នុងតុលាការបាន។ នៅក្នុងរឿងក្តីនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបដិសេធ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ធ្វើ

---

ត្រូវបានធ្វើវិសោធនកម្ម កាលពីថ្ងៃទី០៨ ធ្នូ ២០១០, វិធាន៨០.ខ។ លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ, ឯកសារ អសប , U.N. Doc. A/CPNF.183/9, ចុះថ្ងៃទី១៧ កក្កដា ១៩៩៨, ដែលចូលជាធរមានកាលពីថ្ងៃទី១ កក្កដា ២០០២, មាត្រា៦៣.២។

[12] *សូមអាន ឧទាហរណ៍ដូចជា សូមអាន* ឧទាហរណ៍ដូចជា ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង Milosević,* មូលហេតុដែលនាំឱ្យធ្វើសេចក្តីសម្រេចទាក់ទងនឹងការចាត់តាំងមេធាវី, សំណុំរឿងលេខ IT-02-54-T, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២២ កញ្ញា ២០០៤, កថាខណ្ឌទី៣៣៖ (មិនមានភាពខុសគ្នារវាងការប្រព្រឹត្តិខុសឆ្គងដោយចេតនាដែលធ្វើឱ្យរំខានដល់ដំណើរការនីតិវិធី ហើយនិងកាលៈទេសៈណាមួយផ្សេងទៀតដែលធ្វើឱ្យរំខានដល់ដំណើរការនីតិវិធីបែបនេះ ដែលជាការគំរាមកំហែងដល់សុចរិតភាពនៃសវនាការជំនុំជម្រះក្តីនោះទេ)។

[13] អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ករណីរឿងក្តីរបស់ *Zigiranyirazo,*កថាខណ្ឌទី១១។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ករណីរឿងក្តីរបស់ *Stanišić & Simatović,* កថាខណ្ឌទី៦។

[14] អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ករណីរឿងក្តីរបស់ *Stanišić & Simatović,* កថាខណ្ឌទី៦។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ករណីរឿងក្តីរបស់ *Zigiranyirazo,* កថាខណ្ឌទី១១។

ដូច្នេះ គឺដោយផ្អែកទៅលើមូលដ្ឋាននៃការរកឃើញថា ការធ្វើបដិប្បញ្ញត្តិសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវមានវត្តមានជារូបវន្តដោយផ្ទាល់នៅក្នុង តុលាការមិនសមហេតុសមផលនោះទេក្នុងកាលៈទេសៈនៃករណីរឿងនេះ គឺមិនមែនមកពីអង្គជំនុំជម្រះមិនដែលធ្លាប់បានអនុញ្ញាតទាល់តែសោះក្នុងការបន្តធ្វើសវនាការដោយមិនមានវត្តមានរបស់ជនជាប់ចោទ ដោយសារមូលហេតុសុខភាពទ្រុឌទ្រោមដោយមានជម្ងឺនោះទេ[15]។ជាពិសេសអង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានកំណត់ថា ទោះបីជាសុខភាពមិនល្អ ដោយមានជម្ងឺរបស់ជនជាប់ចោទបានបណ្តាលឱ្យមានការអូសបន្លាយពេលរហូតដល់មួយខែកន្លះ ក្នុងការចាប់ផ្តើមសវនាការក៏ដោយក៏រយៈពេលអូសបន្លាយនេះមិន"ឈានទៅដល់កំរិតមួយដែលមានលក្ខណៈសំខាន់ចាំបាច់ដាច់ខាត ដែលត្រូវតែអនុញ្ញាតឱ្យធ្វើបដិប្បញ្ញត្តិសិទ្ធិ នូវសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដែលត្រូវមានវត្តមាននៅក្នុងពេលសវនាការនោះដែរ"[16]។

១១. វិធានផ្ទៃក្នុង អវតក ក៏អនុញ្ញាតផងដែរឱ្យធ្វើសវនាការដោយមិនមានវត្តមានរបស់ជនជាប់ចោទនៅក្នុងករណីដែលជនជាប់ចោទធ្វើឱ្យរំខានដល់ការធ្វើសវនាការ[17]។ នេះគឺជាការចាំបាច់ត្រូវអនុវត្តចំពោះករណីមានចេតនា ក៏ដូចជាគ្មានចេតនា ដូចជាឈឺថ្កាត់ជាដើម។ តាមពិត នៅក្នុងវិធាន៣៧ នៃវិធានផ្ទៃក្នុង អវតក នៅពេលដែលអ្នកធ្វើសេចក្តីព្រាងវិធាននេះមានបំណងចង់កំរិតអំពីកាលៈទេសៈនានានៃការរំខាន"ដោយចេតនា"នោះ គឺពួកគេបញ្ជាក់ដោយពាក្យពេចន៍ច្បាស់ៗ[18]។ ក៏ប៉ុន្តែនៅក្នុងវិធាន៣៧.២ នៃវិធានផ្ទៃក្នុង អវតក ដែលទាក់ទងនឹងការធ្វើឱ្យរំខានដោយជនជាប់ចោទ គឺមិនឃើញមានការប្រើពាក្យដោយចេតនានោះទេ ដែលហេតុនេះ គឺមិនមែនកំរិតត្រឹមតែការធ្វើឱ្យរំខានដោយចេតនាឡើយ។ ជនជាប់ចោទក៏បានលើកសំអាងផងដែរទៅលើវិធាន៨១នៃវិធានផ្ទៃក្នុង អវតក ដែលចែងថា បើសិនជា ជនជាប់ចោទមិនអាចមានវត្តមានដោយសារមូលហេតុសុខភាព សវនាការអាចបន្តធ្វើបានដោយមានការយល់ព្រមពីជនជាប់ចោទ។ ភាពផ្ទុយគ្នាជាក់ស្តែងរវាងវិធាន៨១ និងវិធាន៣៧.២នៃវិធានផ្ទៃក្នុង អវតក គឺមិនអាចទប់ទល់នឹងការបកស្រាយដែលមានគោលដៅ និងទៅតាមបរិបទនៃវិធានទាំងពីរនេះបានឡើយ។ សហព្រះរាជអាជ្ញា ស្នើយោបល់ថាក្នុងនាមជាបញ្ហាទូទៅមួយ ការយល់ព្រមរបស់ជនជាប់ចោទគឺត្រូវតម្រូវឱ្យមាន សំរាប់សវនាការបន្តធ្វើនៅពេលគាត់អវត្តមានដោយសារបញ្ហាសុខភាពដែលមានការបង្ហាញភស្តុតាង។ ក៏ប៉ុន្តែនៅពេលដែលកាលៈទេសៈឈានទៅដល់ចំណុចចាប់ផ្តើម ដើម្បីឱ្យវិធាន៣៧.២ នៃវិធានផ្ទៃក្នុងអាច

---

[15] អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ករណីរឿងក្តីរបស់ *Stanišić & Simatović,* កថាខណ្ឌទី១៨។

[16] អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ករណីរឿងក្តីរបស់ *Stanišić & Simatović,* កថាខណ្ឌទី១៨។

[17] វិធាន៣៧.២, វិធានផ្ទៃក្នុង អវតក។

[18] សូមអាន ឧទាហរណ៍ដូចជា វិធាន៣៧.៣ នៃវិធានផ្ទៃក្នុង អវតក។

អនុវត្តបាន និងដើម្បីឱ្យការកំរិតទៅលើសិទ្ធិដែលត្រូវមានវត្តមានជារូបវន្តនៅក្នុងពេលសវនាការអាចត្រូវបានអនុញ្ញាតនោះ -គឺនៅពេលមានការធ្វើឱ្យរំខានដល់សវនាការដ៏សំខាន់- អង្គជំនុំជម្រះសាលាដំបូង អាចបញ្ជាឱ្យសវនាការធ្វើបន្តដោយអវត្តមានរបស់ជនជាប់ចោទ និងដោយគ្មានការយល់ព្រមពីជនជាប់ចោទបាន ឱ្យតែការកំរិតទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយមានវត្តមានរបស់ខ្លួនមានសមាមាត្រ។ ការបកស្រាយចំពោះវិធានផ្ទៃក្នុងរបស់ អវតក នេះ គឺស្របគ្នាជាមួយនឹងសេចក្តីសម្រេចរបស់តុលាការអន្តរជាតិនានា ដូចដែលបានកត់សំគាល់ខាងលើទទួលស្គាល់ថា សិទ្ធិត្រូវមានវត្តមាននៅក្នុងសវនាការមិនមែនមិនមានការកំរិតនោះទេ។ ហើយក៏មានការយល់ដឹងផងដែរ អំពីប្រការដែល អវតក ប្រកាន់យកតាមប្រពៃណីនៃប្រព័ន្ធច្បាប់បារាំង ដែលទទួលស្គាល់ថា សិទ្ធិរបស់ជនជាប់ចោទដែលត្រូវមានវត្តមាននៅក្នុងសាលសវនាការគឺមិនមែនដាច់ខាតឡើយ។

១២. អាស្រ័យហេតុនេះ បើសិនជាជនជាប់ចោទបានបង្ហាញភស្តុតាងថា ស្ថានភាពខាងផ្លូវកាយ និងខាងសុខភាពដែលរារាំងមិនឱ្យគាត់ចូលរួមនៅក្នុងសវនាការពេញមួយថ្ងៃបាននោះ សហព្រះរាជអាជ្ញាសូមជូនជាយោបល់ថា អង្គជំនុំជម្រះសាលាដំបូង អាចមានសិទ្ធិអំណាចក្នុងការពិចារណាធ្វើការបញ្ជាឱ្យបន្តធ្វើសវនាការ និងអនុញ្ញាតឱ្យជនជាប់ចោទចូលរួមតាមរយៈបច្ចេកទេសសោតទស្សន៍និងទូរទស្សន៍ផ្សាយផ្ទាល់ពីអង្គភាពមន្ទីរឃុំឃាំងបាន។ ក្នុងករណីនេះ អង្គជំនុំជម្រះគួរយកចិត្តទុកដាក់លើកត្តាទាំងឡាយដូចខាងក្រោមនេះដែលសហព្រះរាជអាជ្ញា សន្និដ្ឋានថា អាចធ្វើយុត្តិកម្មចំពោះករណីលើកលែងមួយដល់សិទ្ធិរបស់ជនជាប់ចោទដែលត្រូវមានវត្តមាននៅក្នុងពេលសវនាការ។

១៣. ទី១ អង្គជំនុំជម្រះសាលាដំបូងគួរប៉ាន់ប្រមាណវាយតម្លៃថា តើការតម្រូវឱ្យជនជាប់ចោទមានវត្តមានជារូបវន្តដោយផ្ទាល់នៅគ្រប់ពេលទាំងអស់នៅក្នុងពេលសវនាការត្រូវបានរំពឹងទុកថា នឹងបណ្តាលឱ្យមានការអូសបន្លាយដ៏វែងនៅក្នុងដំណើរការនីតិវិធីដែរឬទេ?។ នៅក្នុងករណីរឿងក្តីរបស់ *Stanišić & Simatović* ការអូសបន្លាយពេលវេលាគឺរហូតទៅដល់មួយខែកន្លះ។ បើសិនជាកាលៈទេសៈបែបនេះកើតឡើងនៅក្នុងករណីរឿងនេះ អង្គជំនុំជម្រះសាលាដំបូង ចាំបាច់ត្រូវតែធ្វើការកំណត់ថាតើរយៈពេលជាសក្តានុពលនៃអវត្តមានរបស់ជនជាប់ចោទនឹងបណ្តាលឱ្យមានការអូសបន្លាយពេលវេលាដល់សវនាការដ៏វែងដែរឬទេ?

១៤. ទី២ អង្គជំនុំជម្រះសាលាដំបូងគួរពិចារណាថា តើស្ថានភាពដែលរារាំងមិនឱ្យជនជាប់ចោទអាចមានវត្តមានដោយខ្លួនឯងផ្ទាល់ នៅក្នុងសវនាការទំនងជានឹងមានលក្ខណៈស្ថិតនៅយូរដែរឬទេ?

បើសិនជាដូច្នេះ ស្ថានភាពបច្ចុប្បន្នមុខជានឹងមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីករណីរឿងក្តីរបស់ *Stanišić & Simatović* ហើយនិង *Zigiranyirazo* ដែលក្នុងនោះការចូលរួមពីចម្ងាយត្រូវបានគេចាត់ទុកថាមិនត្រូវបានធ្វើយុត្តិកម្មនោះទេ ព្រោះស្ថានភាពដែលរារាំងជនជាប់ចោទមិនឱ្យចូលរួមជារូបវន្តដោយផ្ទាល់នៅក្នុងពេលសវនាការបាននោះ គឺមិនមែនស្ថិតក្នុងកំរិតមួយដែលត្រូវចាត់ទុកថា មានលក្ខណៈជាការស្ថិតនៅយូរឡើយ។

១៥. ទី៣ អង្គជំនុំជម្រះសាលាដំបូង គួរធ្វើការថ្លឹងថ្លែងឱ្យបានត្រឹមត្រូវចំពោះអង្គហេតុពិតជាក់ស្តែងដែលថាការធ្វើឱ្យរំខានដល់ដំណើរការសវនាការ ដែលបណ្តាលមកពីសុខភាពទ្រុឌទ្រោមដោយមានជម្ងឺរបស់ជនជាប់ចោទអាចមិនគ្រាន់តែជាឧបសគ្គរារាំងដ៏ធំដល់ដំណើរការសវនាការជំនុំជម្រះក្តីដោយឆាប់រហ័សប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងអាចរារាំងដល់ អវតក មិនឱ្យឈានទៅសម្រេចបានក្នុងការចេញសាលក្រមស្ថាពរនៅក្នុងករណីរឿងនេះទៀតផង។ ស្ថានភាពបែបនេះគឺជាការផ្ទុយទៅនឹង "ផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងអន្តរជាតិ ក្នុងការបំពេញឱ្យបានចប់សព្វគ្រប់នូវការជំនុំជម្រះក្តីឱ្យបានឆាប់រហ័ស"[19] ក៏ដូចជាគោលបំណងរួមទាំងមូលរបស់ អវតក ដែលត្រូវនាំខ្លួនទៅវិនិច្ឆ័យទោស ចំពោះមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ១៧ មេសា ១៩៧៥ ដល់៦ មករា ១៩៧៩[20]។

១៦. ទី៤ អង្គជំនុំជម្រះសាលាដំបូង គួរធ្វើការថ្លឹងថ្លែងនូវសិទ្ធិរបស់ជនជាប់ចោទដែលត្រូវមានវត្តមាននៅក្នុងពេលសវនាការនេះ ជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទផ្សេងៗទៀតគឺ អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន ("សហជនជាប់ចោទ ") ។ ជាពិសេស សិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវទទួលបានការជំនុំជម្រះក្តីនៅក្នុងពេលវេលាមួយដ៏សមស្រប ដែលអាចនឹងត្រូវបានធ្វើឱ្យអន្តរាយ ដោយការមិនបញ្ជាឱ្យជនជាប់ចោទតាមដានសវនាការ និងឱ្យទាក់ទងគ្នាពីចម្ងាយជាមួយមេធាវីរបស់ខ្លួន

---

[19] ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង Norman,* សេចក្តីសម្រេចលើលើពាក្យសុំរបស់ Samuel Hinga Norman ដែលស្នើសុំធ្វើជាតំណាងការពារក្តីដោយខ្លួនឯងផ្ទាល់, តាមមាត្រា ១៧.៤.ឃ នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន, សំណុំរឿងលេខ SCSL-04-14-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL, ចុះថ្ងៃទី៨ មិថុនា ២០០៤, កថាខណ្ឌទី២៦។

[20] ច្បាប់ អវតក, មាត្រា១។

ពីទីកន្លែងណាមួយ។ សិទ្ធិនេះត្រូវបានធានាដោយមាត្រា៣៥ថ្មី នៃច្បាប់ អវតក, ដោយវិធាន២១.៤ នៃវិធានផ្ទៃក្នុង, និងមាត្រា១៤.៣.គ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

១៧. ជារួមមក សហព្រះរាជអាជ្ញា សូមជូនជាយោបល់ថា ទ្វារនៅបើកចំហរសម្រាប់អង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុញ្ញាតឱ្យជនជាប់ចោទអនុវត្តតាមដំណើរការនៃសវនាការនិងឱ្យទាក់ទងតាមពេលវេលាជាក់ស្តែងជាមួយមេធាវីការពារក្តីរបស់ខ្លួន តាមរយៈបច្ចេកទេសសោតទស្សន៍និងទូរទស្សន៍ផ្សាយផ្ទាល់ បើសិនជាស្ថានភាពអាយុ និងសុខភាពទ្រុឌទ្រោមរបស់គាត់ ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងត្រឹមត្រូវ ធ្វើឱ្យរំខានជាសំខាន់ណាមួយដល់ការធ្វើសវនាការ។ សហព្រះ-រាជអាជ្ញា មិនយល់ស្របទៅលើអ្វីដែលបានលើកឡើងនៅក្នុងញត្តិរបស់ជនជាប់ចោទដែលថា ការចូលរួមពីចម្ងាយអាចអនុញ្ញាតឱ្យធ្វើបានលុះត្រាតែមានការយល់ព្រមពីជនជាប់ចោទនោះឡើយ។

## ៤. សេចក្តីសន្និដ្ឋាន

១៨. អាស្រ័យដោយមូលហេតុដូចដែលបានលើកឡើងខាងលើ សហព្រះរាជាអាជ្ញាសូមស្នើឱ្យ៖

១). អង្គជំនុំជម្រះសាលាដំបូង បដិសេធចោលនូវសំណើរបស់ជនជាប់ចោទដែលសុំឱ្យដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ។

២). បើសិនជាចាំបាច់ សូមឱ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យជនចាប់ចោទចូលរួមនៅក្នុងសវនាការតាមរយៈបច្ចេកទេសសោតទស្សន៍និងទូរទស្សន៍ផ្សាយផ្ទាល់ ពីអង្គភាពមន្ទីរឃុំឃាំង ក្នុងករណីដែលការប្រព្រឹត្តិទៅនៃសវនាការ ត្រូវបានរំខានជាដុំកំភួន ដោយសារស្ថានភាព អាយុ និងសុខភាពរបស់គាត់ ដោយផ្អែកលើភស្តុតាងត្រឹមត្រូវ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |